**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ សហចៅក្រមស៊ើបអង្កេត

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ ២០១៤

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 01-Jul-2014, 14:44
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖ **ប្តូរទៅជាសាធារណៈ**

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**សំណើរបស់ មាស មុត សុំឲ្យដាក់សំណើសុំការពិចារណាទាំងអស់នៅក្នុងសំណុំរឿង**

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាងឧត្តម
Michael G. KARNAVAS

**ចម្លងជូន៖**

**សហចៅក្រមស៊ើបអង្កេត៖**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Mark B. HARMON

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក. តាមរយៈនេះ ស្នើឲ្យសហចៅក្រមស៊ើបអង្កេតដាក់សំណើសុំការពិចារណាទាំងអស់របស់មេធាវីការពារក្តីទៅក្នុងសំណុំរឿងដោយគ្មានការពន្យារពេល។ សំណើនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះសហចៅក្រមស៊ើបអង្កេត Harmon បានបង្គាប់ក្រឡាបញ្ជីនៃ ក.ស.ច.ស. មិនឲ្យដាក់សំណើសុំការពិចារណាទាំងឡាយរបស់មេធាវីការពារក្តីទៅក្នុងសំណុំរឿង និង បានថ្លែងថា "នៅពេលអនាគត ខណៈដែលរង់ចាំសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងទំនាស់ផលប្រយោជន៍ ក្រឡាបញ្ជី ក.ស.ច.ស. នឹងត្រូវបានណែនាំឲ្យបដិសេធការដាក់សារណាបន្ថែមទៀត"[1]។ ឥឡូវនេះ អង្គបុរេជំនុំជម្រះបានសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីទំនាស់ផលប្រយោជន៍ហើយ និង បានទទួលស្គាល់ការតែងតាំងសហមេធាវីផងដែរ[2]។ ដូច្នេះ គ្មានហេតុផលណាដែលថា សំណើសុំការពិចារណាទាំងអស់របស់មេធាវីការពារក្តីមិនគួរត្រូវបានដាក់ក្នុងសំណុំរឿងឲ្យបានរួសរាន់ឡើយ។

**អាស្រ័យហេតុនេះ** តាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមគោរពស្នើសុំសហចៅក្រមស៊ើបអង្កេតមេត្តាដាក់សំណើសុំការពិចារណាទាំងអស់របស់មេធាវីការពារក្តីទៅក្នុងសំណុំរឿង។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **០១** ខែ**កក្កដា** ឆ្នាំ **២០១៤**
សហមេធាវីការពារក្តីលោក មាស មុត

________________ ________________

អាង ឧត្តម Michael G. KARNAVAS

[1] តំណាងក្តីនៃជនសង្ស័យ មាស មុត ("ជនសង្ស័យ") ក្នុងរឿងក្តី ០០៣ ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ A41។

[2] សាលដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ច្រានចោលការតែងតាំង អាង ឧត្តម និង Michael KARNAVAS ជាសហមេធាវី ចុះថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០១៤ ឯកសារ D56/19/36។